ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍

## ស្តីពី

## លទ្ធផលនៃការពិនិត្យការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី១ ឆ្នាំ២០២២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សេចក្តីផ្តើម**:

ឆ្នាំ២០២២ គឺជាឆ្នាំទី៧ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តថវិកាកម្មវិធីពេញលេញដោយឈរលើគោលបំណងគោលនយោបាយរួមមួយគឺ “ ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចិរភាព” ។ ដើម្បីឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តជាកម្មវិធី អនុកម្មវិធីនិងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៦អង្គភាព ក្នុងនោះថ្នាក់កណ្តាលមានចំនួន២១អង្គភាពថវិកានិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន២៥ រាជធានីខេត្ត។

### I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។ នៅក្នុងច្បាប់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងឥណទានចំណាយថវិកា ឆ្នាំ២០២២ សរុបមានចំនួន ២៥៨ ៣២៧ លានរៀល ក្នុងនោះ ៖

(ក) **រដ្ឋបាលកណ្តាល**៖ បានគ្រោងឥណទានចំណាយថវិកាសរុបចំនួន ១៦២ ៤២១ លានរៀល រួមមាន៖

- ឥណទានចំណាយថវិកាចរន្ត មានចំនួន ១៥៣ ៤២១ លានរៀល
- ឥណទានចំណាយថវិកាមូលធន មានចំនួន ៩ ០០០ លានរៀល

(ខ) **មន្ទីររាជធានី ខេត្ត** ៖បានគ្រោងឥណទានចំណាយថវិកាចរន្តសរុបចំនួន ៩៥ ៩០៦ លានរៀល

### II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ នៅក្នុងត្រីមាសទី១ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អនុវត្តចំណាយ តាមអាណត្តិបើកប្រាក់សរុបចំនួន៤៦ ៦៣០,៨ លានរៀល ស្មើនឹង១៨,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ក្នុងនោះរដ្ឋបាលកណ្តាលអនុវត្តបានចំនួន២៩ ៤០៣លានរៀល ស្មើនឹង១៨,១%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៧៨,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។ រីឯមន្ទីររាជធានី ខេត្តអនុវត្តបានចំនួន ១៧ ២២៧,៨លានរៀល ស្មើនឹង១៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ឬស្មើនឹង៧៥,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

**(ក) រដ្ឋបាលកណ្តាល៖**

ដោយពិនិត្យទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា ការអនុវត្តចំណាយតាមអាណត្តិបើកប្រាក់របស់រដ្ឋបាលកណ្តាល (២១អង្គភាពថវិកា) សម្រេចបានចំនួន២៩ ៤០៣ លានរៀល ដោយក្នុងនោះ (ក)ការទិញ

(ជំពូក៦០) អនុវត្តបានចំនួន១ ១៩៤,៩ លានរៀល ស្មើនឹង៥,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៣៦,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន១ ២៣១,៣លានរៀល ស្មើនឹង៣,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង២៤,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ)បន្ទុកបុគ្គលិក(ជំពូក៦៤) អនុវត្តបានចំនួន១៤ ៩៣៧,៩ លានរៀល ស្មើនឹង២០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៦៣,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ) ឧបត្ថម្ភធន (ជំពូក៦៥) អនុវត្តបានចំនួន៨ ១២១,១លានរៀល ស្មើនឹង៣៥,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១៤២,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង)ចំណាយមូលធន (ជំពូក២១) អនុវត្តបានចំនួន ៣ ៩១៧,៨លានរៀលស្មើនឹង៤៣,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ។

ម្យ៉ាងវិញទៀត ដោយពិនិត្យលើចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់អង្គភាពរដ្ឋបាលកណ្តាល ឃើញថា ទឹកប្រាក់សរុបចំនួន២៩ ៤០៣ លានរៀល នេះត្រូវបានអនុវត្តចំណាយសម្រាប់៖

(១) បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម និងកសិធុរកិច្ច (កម្មវិធីទី១) ចំនួន៧ ៦៥៤,៨លានរៀល ស្មើនឹង ២២,៩%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

(២) ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ ( កម្មវិធីទី២) ចំនួន៣១៧,៩ លានរៀល ស្មើនឹង២,៨% ធៀបនឹង ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

(៣) គ្រប់គ្រងធនធានជលផលនិងអភិវឌ្ឍវារីវប្បកម្ម (កម្មវិធីទី៣) ចំនួន៦៥១,៩ លានរៀល ស្មើនឹង៦%ធៀបនឹង ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

(៤) គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ (កម្មវិធីទី៤) ចំនួន ៥១៦,៦លានរៀល ស្មើនឹង៦,២ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

(៥) បង្កើនប្រសិទ្ធភាពសេវាគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស(កម្មវិធីទី៥) ចំនួន២០ ២១៦,៨លានរៀល ស្មើនឹង២០,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ។

**(ខ) មន្ទីររាជធានី ខេត្ត ៖**

យោងតាមការពិនិត្យការអនុវត្តចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង២៥ រាជធានី ខេត្ត បានអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់សរុបមានចំនួន ១៧ ២២៧,៨ លានរៀល គឺអនុវត្តបានទាបជាងឆ្នាំ២០២១ក្នុងរយៈពេលដូចគ្នា ប្រមាណជា២% ក្នុងនោះចំណាយលើ (ក) ការទិញ (ជំពូក៦០) អនុវត្តបានចំនួន២ ១៦៥,៩ លានរៀល ស្មើនឹង១៩,៩ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ឬស្មើនឹង៧៥,៣% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន២ ៣២១,១លានរៀលស្មើនឹង១០,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៤៧,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ(គ) បន្ទុកបុគ្គលិក (ជំពូក៦៤) អនុវត្តបានចំនួន១១ ៦៥៥,៣ លានរៀល ស្មើនឹង២១,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៨៥,៣% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ) អត្ថប្រយោជន៍សង្គម (ជំពូក៦២) អនុវត្តបានចំនួន១ ០៨៥,៥ លានរៀល ស្មើនឹង១៤,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៧៣,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង) ជំពូក៦៣ (ពន្ធនិងអាករ) មិនទាន់បានអនុវត្តនៅឡើយនៅក្នុងត្រីមាសទី១នេះ។

ម្យ៉ាងទៀត ដោយពិនិត្យទៅតាមចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិកា តួលេខអនុវត្តចំណាយថវិកាសរុប ចំនួន ១៧ ២២៧,៨ លានរៀល ត្រូវបានអនុវត្តដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តដូចខាងក្រោម៖

ឯកតា: រៀល

| មន្ទីររាជធានី ខេត្ត | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ | កម្មវិធី ត្រីមាសទី១ | ការអនុវត្ត ត្រីមាសទី១ | %ធៀបច្បាប់ហិរញ្ញវត្ថុ ២០២២ | %ធៀបកម្មវិធី ត្រីមាសទី១ |
|---|---|---|---|---|---|
| បន្ទាយមានជ័យ | 3 820 600 000 | 1 468 475 000 | 398 882 668 | 10.4% | 27.2% |
| បាត់ដំបង | 6 327 800 000 | 1 670 750 000 | 1 607 931 590 | 25.4% | 96.2% |

| | | | | | |
|---|---|---|---|---|---|
| កំពង់ចាម | 4 035 000 000 | 949 280 000 | 612 166 360 | 15.2% | 64.5% |
| កំពង់ឆ្នាំង | 3 862 500 000 | 775 000 000 | 622 836 400 | 16.1% | 80,4% |
| កំពង់ស្ពឺ | 4 513 600 000 | 840 200 000 | 721 762 010 | 15.9% | 85,9% |
| កំពង់ធំ | 5 498 500 000 | 1 586 125 000 | 1 087 928 500 | 19.8% | 68.6% |
| កំពត | 3 933 400 000 | 783 000 000 | 667 256 260 | 16.9% | 85.2% |
| កណ្ដាល | 6 123 700 000 | 1 696 768 000 | 1 541 847 617 | 25.9% | 90.9% |
| កោះកុង | 2 432 100 000 | 546 310 000 | 265 650 000 | 10.9% | 48.6% |
| ក្រចេះ | 3 943 600 000 | 1 017 600 000 | 886 966 463 | 22.5% | 87.2% |
| មណ្ឌលគិរី | 2 774 100 000 | 482 050 000 | 280 369 100 | 10.1% | 58.2% |
| រាជធានីភ្នំពេញ | 3 843 300 000 | 865 310 000 | 534 323 210 | 13.9% | 61.8% |
| ព្រះវិហារ | 2 713 100 000 | 591 449 000 | 501 942 600 | 18.5% | 84.9% |
| ព្រៃវែង | 4 357 400 000 | 776 103 000 | 732 928 010 | 16.8% | 94.4% |
| ពោធិ៍សាត់ | 3 822 100 000 | 1 496 964 000 | 549 723 900 | 14.4% | 36.7% |
| រតនគិរី | 3 147 100 000 | 513 000 000 | 508 089 800 | 16.1% | 99% |
| សៀមរាប | 5 700 600 000 | 1 145 789 000 | 805 035 200 | 14.1% | 70.3% |
| ព្រះសីហនុ | 2 833 700 000 | 606 000 000 | 345 652 960 | 12.2% | 57% |
| ស្ទឹងត្រែង | 3 315 900 000 | 380 000 000 | 1 263 584 900 | 38.1% | 332.5% |
| ស្វាយរៀង | 2 998 400 000 | 593 975 000 | 460 033 300 | 15.4% | 77.5% |
| តាកែវ | 5 407 600 000 | 1360 950 000 | 777 731 590 | 14.4% | 57.2% |
| ឧត្ដរមានជ័យ | 2 994 800 000 | 1 226 143 000 | 1 117 583 000 | 37.3% | 91.2% |
| កែប | 1 646 100 000 | 388 100 000 | 176 412 500 | 10.7% | 45.5% |
| ប៉ៃលិន | 2 161 100 000 | 415 500 000 | 364 098 610 | 16.9% | 87.6% |
| ត្បូងឃ្មុំ | 3 699 900 000 | 726 900 000 | 397 113 130 | 10.7% | 54.6% |

## III-**បញ្ហាប្រឈម**

យោងតាមការអធិប្បាយខាងលើឃើញថា ការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី១ឆ្នាំ២០២២ សម្រេចបានទាបជាងឆ្នាំ២០២១ ដោយសារអង្គភាពថវិកាទាំងអស់ត្រូវបន្តអនុវត្តតាមប្រកាសណែនាំស្ដីពីនីតិវិធីថ្មីៗពាក់ព័ន្ធការចំណាយរដ្ឋទេយ្យបុរេប្រទាន ការចំណាយប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស ការចំណាយរៀបចំវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា សន្និសិទ និងកិច្ចប្រជុំផ្សេងៗ ។ ការងារនេះតម្រូវឲ្យអង្គភាពថវិកានីមួយៗសិក្សាស្វែងយល់ឲ្យបានច្បាស់លាស់ និងត្រូវរៀបចំឯកសារពាក់ព័ន្ធមួយចំនួនទំរាំអាចអនុវត្តការចំណាយបាន។

ទន្ទឹមនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជួបបញ្ហាប្រឈមមួយចំនួនដែលធ្វើឲ្យដំណើរការចំណាយមានការយឺតយ៉ាវខ្លះៗ ទាំងចំណាយចរន្តនិងចំណាយមូលធនដែលបញ្ហាលំបាកទាំងនោះមានដូចជា៖

-ការផ្ដល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភាពយឺតយ៉ាវដែលនាំឲ្យរាំងស្ទះដល់ការងារអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ។

-ឯកសារគាំទ្រសម្រាប់ជម្រះទូទាត់រដ្ឋទេយ្យបុរេប្រទានរបស់អង្គភាពថវិកាមួយចំនួន មិនទាន់បំពេញបានគ្រប់គ្រាន់ និងទាន់ពេលវេលា។

## IV-**ទិសដៅអនុវត្តបន្ត**

អង្គភាពថវិកានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវខិតខំអនុវត្តចំណាយថវិកាក្នុងការធ្វើសកម្មភាពការងារដើម្បីសម្រេចបានសូចនាកររបស់ខ្លួនទៅតាមកម្មវិធីចំណាយប្រចាំត្រីមាសទី២ឆ្នាំ២០២២ ដែលមានទឹកប្រាក់សរុបចំនួន ៦៩ ៩០៦ ៤៨៥ ០០០ រៀល ក្នុងនោះរួមមាន ៖

ឯកតា: រៀល

| ចំណាត់ថ្នាក់សេដ្ឋកិច្ច | រដ្ឋបាលកណ្តាល | មន្ទីររាជធានី ខេត្ត |
|---|---|---|
| ជំពូក ៦០ (ការទិញ) | 4 657 700 000 | 6 687 198 000 |
| ជំពូក ៦១ (សេវាកម្ម) | 2 100 000 000 | 9 385 062 000 |
| ជំពូក ៦៤ (បន្ទុកបុគ្គលិក) | 21 620 000 000 | 14 500 968 000 |
| ជំពូក៦២(អត្ថប្រយោជន៍សង្គម) | - | 5 266 157 000 |
| ជំពូក ៦៥ (ឧបត្ថម្ភធន) | 5 622 000 000 | - |
| ជំពូក ៦៣ (ពន្ធនិងអាករ) | 50 000 000 | 17 400 000 |
| **សរុប** | **34 049 700 000** | **35 856 785 000** |

## V-**សេចក្តីសន្និដ្ឋាន**

ឆ្លងតាមការពិនិត្យវាយតម្លៃការអនុវត្តចំណាយថវិកា ប្រចាំត្រីមាសទី១ របស់អង្គភាពថវិកានៃរដ្ឋបាលកណ្តាល ជារួមសម្រេចបាន៧៨,១% នៃកម្មវិធីដែលបានដាក់ចេញ លទ្ធផលនេះបានមកដោយសារការអនុវត្តចំណាយឧបត្ថម្ភធន(ជំពូក៦៥)អនុវត្តលើសកម្មវិធីត្រីមាសទី១ប្រមាណជា៤២% និងចំណាយមូលធនអនុវត្តបាន៤៣,៥%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ រីឯការចំណាយលើបន្ទុកបុគ្គលិក(ជំពូក៦៤) អនុវត្តបានទាបជាងកម្មវិធីចំណាយប្រមាណ ៣៦% ចំណាយលើការទិញ(ជំពូក៦០)អនុវត្តបានទាបជាងកម្មវិធីប្រមាណជា៦៣% និងចំណាយសេវាកម្ម(ជំពូក៦១) អនុវត្តបានទាបជាងកម្មវិធីប្រមាណជា៧៥% ទាំងនេះគឺដោយសារ(១)ដំណើរការទូទាត់ចំណាយតាមនីតិវិធីលទ្ធកម្ម ក្នុងកំឡុងពេលនេះមិនទាន់ដល់ពេល (២) ការទូទាត់ចំណាយបុរេប្រទាន និងរដ្ឋទេយ្យបុរេប្រទានមានតិចតួចដោយសារមានការកែសម្រួលនីតិវិធីអនុវត្ត ដោយឡែកចំណាយបង់ពន្ធរថយន្ត (ជំពូក៦៣) មិនទាន់បានអនុវត្តនៅឡើយ។

ចំពោះការអនុវត្តចំណាយថវិការបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមសម្រេចបានបង្គួរ ក្នុងកម្រិត៧៥,២%នៃកម្មវិធីដែលបានដាក់ចេញ។ ទោះបីជាយ៉ាងនេះក្តីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ចំនួនបួនគឺខេត្តបន្ទាយមានជ័យ ពោធិសាត់ កោះកុងនិងខេត្តកែបអនុវត្តចំណាយថវិកាបានទាបធៀបនឹងកម្មវិធី ដែលត្រូវធ្វើការជំរុញនិងកែលម្អបន្ថែមទៀត។

សរុបសេចក្តីមក ការអនុវត្តចំណាយថវិកា តាមអាណត្តិបើកប្រាក់ប្រចាំត្រីមាសទី១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមនៅតែទទួលបានលទ្ធផលល្អបង្គួរ ទោះបីជាមានការកែសម្រួលនីតិវិធីមួយចំនួននិងធ្វើឲ្យការអនុវត្តចំណាយលើការទិញនិងចំណាយសេវាកម្មអនុវត្តបានទាបក្តី ។ ម៉្យាងទៀតចំណាយប្រភេទនេះនឹងកើនឡើងក្នុងត្រីមាសបន្ទាប់ប្រសិនបើស្ថានភាពនៃការឆ្លងជម្ងឺកូវីដ-១៩ បានធូរស្រាល គួបផ្សំនឹងការទូទាត់ចំណាយអនុវត្តនីតិវិធីលទ្ធកម្មមួយចំនួនដូចជាការទូទាត់ចំណាយប្រេង ថ្នាំចាក់ការពារសត្វ(វ៉ាក់សាំង)ប្រចាំឆមាសទី១និងការទូទាត់បុរេប្រទាន និងរដ្ឋទេយ្យបុរេប្រទានជាដើម។

ថ្ងៃ ... ខែ ... ឆ្នាំ ខាល ចត្វាស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២

**អនុរដ្ឋលេខាធិការ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ញ៉ោ រស្មី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណូលថវិកា ប្រចាំត្រីមាសទី១ ឆ្នាំ២០២២
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២១ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណូលឆ្នាំ២០២២ សរុបមានចំនួន ៣៧ ១៤៤,៨ លានរៀល ក្នុងនោះ ៖

(ក) **រដ្ឋបាលកណ្តាល**៖ បានគ្រោងចំណូលសរុបចំនួន ៣៧ ១៤៣,៤ លានរៀល ចំណូលនេះរួមមាន :

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន២០ ៩៩២ លានរៀល ស្មើនឹង១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ (២) ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន ១២ ៨៣១,៤ លានរៀល ស្មើនឹង១១៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១(៣) ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៣ ៣២០ លានរៀល ស្មើនឹង១០១,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ។

(ខ) **មន្ទីររាជធានី ខេត្ត**៖ បានគ្រោងចំណូលសរុបចំនួន១,៤ លានរៀល ស្មើនឹង ១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ចំណូលនេះបានពីការជួលដីទំនេរនៃផលទុនពីការលក់ជួលទ្រព្យសម្បត្តិនិងសេវារបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ។

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ នៅក្នុងត្រីមាសទី១ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តប្រមូលចំណូល សរុបមានចំនួន ៩ ៨០១,៦ លានរៀល ស្មើនឹង២៦,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១០០,៧,%ធៀបនឹងកម្មវិធីដែលបានដាក់ចេញក្នុងនោះ ៖

(ក) **រដ្ឋបាលកណ្តាល**៖ អនុវត្តប្រមូលចំណូល សរុបមានចំនួន៩ ៨០១,៦លានរៀល ស្មើនឹង២៦,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ឬស្មើនឹង៣១០០,៤%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ចំណូលនេះរួមមាន (១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន៣ ៤៦៣ លានរៀល ស្មើនឹង១៦,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៧៤,៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (២) ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន៥ ៦៥៦,៨ លានរៀល ស្មើនឹង៤៤,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១៣៦,១%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៣) ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៥៨៩,៥ លានរៀល ស្មើនឹង១៧,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៦១,៩ % ធៀបនឹងកម្មវិធីដែលបានដាក់ចេញ(៤)ផលហិរញ្ញវត្ថុ មានចំនួន ៩២,៣លានរៀល ដែលជាចំណូលបានមកពីការបង់សំណោសចំណាយប្រាក់បៀវត្ស។



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

(ខ) **មន្ទីររាជធានី ខេត្ត ៖**

នៅក្នុងត្រីមាសទី១នេះមន្ទីរមិនទាន់បានអនុវត្តចំណូលពីថ្លៃឈ្នួលដីទេ។

ជារួមការអនុវត្តចំណូល របស់រដ្ឋបាលកណ្តាលសម្រេចបានល្អស្របទៅតាមកម្មវិធីដែលបានដាក់ចេញ ម៉្យាងទៀតដោយពិនិត្យទៅតាមប្រភេទចំណូលនីមួយៗឃើញថាមានភាពរលូនធៀបនឹងកម្មវិធីដែលបានដាក់ចេញដូចជា៖

(១) ផលទុននៃទ្រព្យសម្បត្តិរដ្ឋអនុវត្តបាន៧៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ករណីនេះបណ្តាលមកពីចំណូលផលពីព្រៃឈើអនុវត្តបាន១៩,១%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៨៧,៦%ធៀបនឹងកម្មវិធីដែលបានដាក់ចេញនិងចំណូលពីសម្បទានដីសេដ្ឋកិច្ចអនុវត្តបាន១៤,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៦៤,៦%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវា អនុវត្តបានខ្ពស់គឺដោយសារចំណូលពីការលក់ឯកសារ លតាប័ត្រនិងលិខិតបោះពុម្ពផ្សេងៗអនុវត្តបាន៤៧,៤% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង២៨៤,៧%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។ ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាលនិងការគ្រប់គ្រងរដ្ឋបាលផ្សេងៗអនុវត្តបានចំនួន ៩៦,៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។ ចំពោះការជួលទ្រព្យសម្បត្តិរដ្ឋដូចជាការជួលដីទំនេរ និងដីមានអគារអនុវត្តបាន១២២,២%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ដោយឡែកចំណូលផលពីការគ្រប់គ្រងរដ្ឋបាលដែលបានពីការត្រួតពិនិត្យអនាម័យសត្វនិងការត្រួតពិនិត្យគុណភាពផលិតផល អនុវត្តបាន៤៧,៧%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១៣៩,៨%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(៣) ចំណូលពីការផាកពិន័យនិងដាក់ទណ្ឌកម្មអនុវត្តបាន១៧,៨%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៦១,៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ លទ្ធផលនេះបានមកដោយសារការផាកពិន័យលើផលិតផលសាច់សត្វ និងការដឹកជញ្ជូនសត្វរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ អនុវត្តបាន៥0 % នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១00%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើការនេសាទខុសច្បាប់ អនុវត្តបាន២៤៤,៥%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៣៩១,២%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ និងការពិន័យលើបទល្មើសព្រៃឈើ អនុវត្តបាន១៩,១ % នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៨៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។

## III-**ទិសដៅអនុវត្តបន្ត**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តខិតខំនិងជំរុញការប្រមូលចំណូលបង់ចូលថវិកាជាតិស្របទៅតាមកម្មវិធីចំណូលប្រចាំត្រីមាសទី២ឆ្នាំ២០២២ ដែលមានទឹកប្រាក់សរុបចំនួន៨ ៣៤៧,៩លានរៀល។ កិច្ចការបន្ទាន់មួយទៀតដែលក្រសួងត្រូវអនុវត្ត គឺបន្តរៀបចំឯកសារកែសម្រួលកម្រងសេវាសាធារណៈនិងសេចក្តីព្រាងប្រកាសអន្តរក្រសួងដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## IV-**សេចក្តីសន្និដ្ឋាន**

សរុបសេចក្តីមកការអនុវត្តប្រមូលចំណូលប្រចាំត្រីមាសទី១ របស់រដ្ឋបាលកណ្តាលសម្រេចបានលទ្ធផលល្អប្រសើរគឺលើសផែនការធៀបនឹងកម្មវិធីដែលបានដាក់ចេញទាំងផ្នែកចំណូលពីសេវាសាធារណៈ និងការជួលដីធ្លី អគារ ។ទន្ទឹមនេះចំណូលពីការលក់ផលិតផលកសិកម្មដូចជាការលក់កូនជ្រូក ពោត សណ្តែក និងស្រូវពូជ ។ល។ មិនទាន់បានអនុវត្តនៅឡើយ។

ម៉្យាងទៀតមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺក៏នៅមិនទាន់បានអនុវត្តប្រមូលចំណូលពីថ្លៃឈ្នួលដីទំនេរផងដែរ។

ដូច្នេះដើម្បីអនុវត្តប្រមូលចំណូលឲ្យបានតាមផែនការឆ្នាំ២០២២ អង្គភាពពាក់ព័ន្ធទទួលបន្ទុកប្រមូលចំណូលត្រូវ

បន្តការយកចិត្តទុកដាក់ក្នុងការប្រមូល និងបង់ចំណូលឲ្យបានទាន់ពេលវេលា គួបផ្សំនឹងការប្រតិបត្តិតាមនីតិវិធីថ្មីៗពាក់ព័ន្ធការបង់ចំណូលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២

**អនុរដ្ឋលេខាធិការ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**